**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៦៥.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៦៨៥ ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ស្ថិតនៅក្នុងភូមិសាស្រ្ត ស្រុកកែវសីមា ខេត្តមណ្ឌលគិរី

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ៩៨ អនក្រ.បកចុះ ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

## សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ៨.៦៨៥ (ប្រាំបីពាន់ប្រាំមួយរយប៉ែតសិបប្រាំ)ហិកតាក្នុងតំបន់ជម្រកសត្វព្រៃភ្នំព្រេច ស្ថិតក្នុងភូមិសាស្ត្រស្រុកកែវសីមា ខេត្តមណ្ឌលគីរី ក្រោមល័ក្ខខ័ណ្ឌ ជួល ឬ សម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្មដូចមានក្នុងផែនទី និង និយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៥៨៣សជណ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១១របស់ទីស្ដីការគណៈរដ្ឋមន្ត្រីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្លួសចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

បណ្ណាគារ ភក្ដីឡង់
PheakdeyLaw Book Store

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៤
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ

www.pheakdeylaw.com